TRANSPARENCY INTERNATIONAL Cambodia

# សេចក្តីថ្លែងការណ៍ព័ត៌មាន

# ទិវាប្រយុទ្ធប្រឆាំងអំពើពុករលួយ ៩ធ្នូ ឆ្នាំ២០២០

## “យកឈ្នះជំងឺកូវីដ-១៩ប្រកបដោយសុចរិតភាព”

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០

ស្របពេលដែលពិភពលោកកំពុងតែជួបប្រទះនឹងវិបត្តិជំងឺកូវីដ-១៩ អំពើពុករលួយត្រូវបានគេសន្មត់ថា ជាឧបសគ្គដ៏ធំមួយក្នុងការប្រយុទ្ធនឹងបញ្ហាជំងឺរាតត្បាតសកលនេះ។ ការប្រយុទ្ធនឹងជំងឺកូវីដ-១៩ប្រកបដោយប្រសិទ្ធភាព និងបរិយាបន្នអាចសម្រេចទៅបាន លុះត្រាតែមានជាតុផ្សំសុចរិតភាព និងគណនេយ្យភាព។ នៅថ្ងៃនេះ អង្គការតម្លាភាពកម្ពុជា មានសេចក្តីសោមនស្សក្នុងការចូលរួមអបអរសាទរទិវាប្រយុទ្ធប្រឆាំងអំពើពុករលួយ ៩ធ្នូ ឆ្នាំ២០២០ ក្នុងចលនាជាសកល ក្រោមប្រធានបទ “**យកឈ្នះជំងឺកូវីដ-១៩ប្រកបដោយសុចរិតភាព**”។

ក្នុងឱកាសអបអរសាទរទិវាប្រយុទ្ធប្រឆាំងអំពើពុករលួយ ៩ធ្នូ ឆ្នាំ២០២០ អង្គការតម្លាភាពកម្ពុជាបានរៀបចំកិច្ចពិភាក្សាទៅលើប្រធានបទធំៗចំនួនពីរ៖ សុចរិតភាពធុរកិច្ចក្នុងអំឡុងពេលជំងឺកូវីដ-១៩ និង ការចូលរួមរបស់ប្រជាពលរដ្ឋ និងយុវជនក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយក្នុងអំឡុងវិបត្តិជំងឺកូវីដ-១៩។

អាជីវកម្មជាច្រើនកំពុងប្រឈមមុខនឹងការផ្អាក ឬបញ្ឈប់ប្រតិបត្តិការ ក្នុងអំឡុងពេលនៃការជាប់គាំងចរន្តសេដ្ឋកិច្ចនៅក្នុង និងក្រៅប្រទេសដោយសារតែបញ្ហាជំងឺកូវីដ-១៩ និងការឃាយីពីអំពើពុករលួយ។ តួយ៉ាង សហគ្រាសធុនតូចនិងមធ្យមដែលពុំសូវមានធនធានដើម្បីទប់ទល់ ដោះស្រាយ និងសម្របខ្លួនទៅនឹងវិបត្តិសេដ្ឋកិច្ច គឺមានភាពងាយរងគ្រោះ ក៏ដូចជាប្រឈមមុខនឹងអំពើពុករលួយតាមទម្រង់ផ្សេងៗ ដូចជាការប្រកួតប្រជែងមិនស្មើភាព ការធ្វើលទ្ធកម្មបែបបក្សពួកនិយម និងការគេចវេសកាតព្វកិច្ចច្បាប់ជាដើម ដែលបង្ហាញពីតម្រូវការដ៏ចាំបាច់ក្នុងការលើកកម្ពស់សុចរិតភាពក្នុងវិស័យធុរកិច្ច និងបរិយាកាសអាជីវកម្មត្រឹមត្រូវ និងមានតម្លាភាពដើម្បីបង្កើតលក្ខណៈប្រកួតប្រជែងដោយយុត្តិធម៌សម្រាប់អាជីវកម្មតូចធំគ្រប់ប្រភេទ។

សម្រាប់ប្រជាជនវ័យក្មេង ជាពិសេសក្រុមយុវជនដែលងាយរងគ្រោះ វិបត្តិជំងឺកូវីដ-១៩បានបង្កហានិភ័យគួរឱ្យកត់សម្គាល់ទៅលើការអប់រំ ការងារ សុខភាពរាងកាយ និងផ្លូវចិត្ត អាហាររូបត្ថម្ភ និងប្រាក់ចំណូលរបស់ពួកគេជាដើម នេះបើតាមការសិក្សានាពេលថ្មីៗនេះរបស់អង្គការOECD លើប្រធានបទ យុវជន និងជំងឺកូវីដ-១៩។ វិសមភាព ដូចជាការបាត់បង់ឱកាស និងការមិនសូវទទួលបានឱកាស គឺជាបញ្ហាចម្បងមួយសម្រាប់យុវជនកម្ពុជា។ យោងតាមអង្គការយូនីសេហ្វកម្ពុជា ដោយសារជំងឺកូវីដ-១៩ កុមារ និងយុវជននៅប្រទេសកម្ពុជាប្រមាណជាង ៣លាននាក់ បានរងផលប៉ះពាល់ពីការបិទសាលារៀន ហើយនេះបានប៉ះពាល់ធ្ងន់ធ្ងរដល់ការអភិវឌ្ឍសមត្ថភាព និងការចូលរួមរបស់យុវជនជាពិសេសចំពោះអ្នកដែលរស់នៅតាមទីជនបទ។ ដើម្បីដោះស្រាយបញ្ហាវិសមភាពនេះ រដ្ឋាភិបាលចាំបាច់អនុវត្តយន្តការ

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia

អភិបាលកិច្ចប្រកបដោយបរិយាបន្ន និងមានប្រសិទ្ធភាព ដោយផ្តោតលើតម្លាភាព និងសុចរិតភាពជាធាតុស្នូល។ ហើយការចូលរួមរបស់យុវជនក្នុងការឃ្លាំមើល និងទាមទារឱ្យសង្គមមួយគ្មានអំពើពុករលួយ គឺជាការចាំបាច់ និងគួរតែត្រូវបានលើកទឹកចិត្តដោយអាដ្ឋាធរ។

ដោយសារគណនេយ្យភាព និងតម្លាភាព គឺជាគោលការណ៍សំខាន់នៃអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងអំពើពុករលួយ និងជាមូលដ្ឋានគ្រឹះក្នុង**ការយកឈ្នះជំងឺកូវីដ-១៩ប្រកបដោយសុចរិតភាព** អង្គការតម្លាភាពកម្ពុជាសូមស្នើដល់រាជរដ្ឋាភិបាលកម្ពុជាបន្តកិច្ចខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ប្រកបដោយប្រសិទ្ធភាព និងបរិយាបន្ន ខណៈដែលមិនបន្ធូរដៃក្នុងការទប់ស្កាត់អំពើពុករលួយ ដើម្បីជានានូវសមភាពសង្គមកាន់តែប្រសើរ។

**លោក ប៉ិច ពិសី** នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា មានប្រសាសន៍ថា៖ "វិបត្តិជំងឺកូវីដ-១៩បាន និងកំពុងធ្វើឱ្យប្រទេសកម្ពុជា និងប្រទេសផ្សេងទៀតជុំវិញពិភពលោកមានហានិភ័យកាន់តែខ្ពស់ពាក់ព័ន្ធនឹងអំពើពុករលួយ និងការបំពាននីតិរដ្ឋ។ តួយ៉ាង មន្ត្រីសាធារណៈ និងអ្នកជំនួញមួយចំនួនតូចឆ្លៀតឱកាសនេះប្រព្រឹត្តអំពើពុករលួយតាមរូបភាពផ្សេងៗដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ឬក្រុមរបស់ខ្លួន។ នេះក៏ដោយសារតែមនុស្សភាគច្រើនបានបង្វែរការយកចិត្តទុកដាក់មកលើវិបត្តិជំងឺកូវីដ-១៩ ជាហេតុធ្វើឱ្យការអនុវត្តយន្តការអភិបាលកិច្ចរបស់រដ្ឋ ឬក្រុមហ៊ុនអាជីវកម្មមានចន្លោះប្រហោងថែមមួយកម្រិតទៀត ស្របពេលដែលការចូលរួមពីសាធារណជន និងភាគីពាក់ព័ន្ធក្នុងការតាមដានលើបញ្ហានេះក៏មានភាពចុះខ្សោយផងដែរ"។ **លោក ប៉ិច ពិសី** បន្តថា៖ "ការផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាពរបស់រដ្ឋាភិបាលកាន់តែទូលំទូលាយ ការផ្តល់ឱកាស និងលើកទឹកចិត្តដល់ភាគីពាក់ព័ន្ធ ជាពិសេសប្រជាពលរដ្ឋទូទៅ និងយុវជនក្នុងការចូលរួមដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងតាមដានប្រសិទ្ធភាពនៃការអនុវត្តច្បាប់របស់មន្ត្រីសាធារណៈ នឹងជួយឱ្យរដ្ឋាភិបាលយកឈ្នះជំងឺកូវីដ-១៩ប្រកបដោយសុចរិតភាព"៕

###

*អង្គការតម្លាភាពអន្តរជាតិ គឺជាអង្គការសង្គមស៊ីវិលឈានមុខក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។*

**Transparency International Cambodia**
#13, Street 554, Sangkat Beung Kak 1, Khan Toul Kork, Phnom Penh, Cambodia

Website: www.ticambodia.org
Email: info@ticambodia.org
Phone: (+855) 23 88 36 81
(+855) 23 88 36 82

**International Secretariat**
Alt-Moabit 96, 10559 Berlin, Germany
www.transparency.org